# អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
## ELECTRICITY LAW OF THE KINGDOM OF CAMBODIA

**សេចក្តីសម្រេចកែសម្រួលលើកទី៥**
**លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០៥៥ឯអ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣**
**សម្រាប់លោក ម៉ាក់ ខុម ធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនី**
**នៅទីប្រជុំជនផ្សារព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ**
**សម្រាប់ពង្រីកតំបន់ចែកចាយ**

DECISION ON FIRTH REVISION
TO THE CONSOLIDATED LICENSE N$^0$ 055 LD DATED OCTOBER 07, 2003
FOR Mr. MAK KHOM FOR PROVIDING ELECTRIC POWER GENERATION AND DISTRIBUTION SERVICES AT PHSAR PREY SANDEK TOWN, KHUM PREY SLEUK, TRANG DISTRICT, TAKEO PROVINCE
FOR EXTENDING DISTRIBUTION AREA

**ថ្ងៃទី... ខែ... ឆ្នាំ២០០...**
**..., 200...**

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**NATION RELIGION KING**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

លេខ : -០៩ អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៥

# លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០៥៥ ឯអ

# ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣

# សម្រាប់លោក ម៉ាក់ ខុម សម្រាប់ពង្រីកតំបន់ចែកចាយ

# DECISION ON FIVE REVISION ON THE CONSOLIDATED LICENSE DOCUMENT N⁰ 055 LD DATED OCTOBER 07, 2003 FOR MR. MAK KHOM FOR EXTENDING DISTRIBUTION AREA

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated 02/02/2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ ០៥៥ឯអ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣

- In accordance with License Documents No. 055 LD Dated October 07, 2003.

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក **ម៉ាក់ ខុម** ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩

-In accordance with the application for extending distribution area Mr. Mak Khom dated May 21, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០០៩ ដល់ថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the consultation with concerned parties and public, made from ..., 2009 to ...., 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៩

- In accordance with the decision of Electricity Authority of Cambodia’s Session No. ..., dated ..., 2009.

## សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០៥៥ ឯអ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣ ដោយអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ដែលមានស្រាប់គឺស្ថិតនៅសង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ។ | **Article 1**<br>To revise License N° 055 LD dated October 07, 2003 to give the right to licensee to extend the existing distribution area at Sangkat Rokarkrav, Dounkeo Town, Takeo Province as show in the map attached in new revised schedule 1. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី១ចាស់របស់ឯកសារអាជ្ញាប័ណ្ណលេខ ០៥៥ ឯអ នឹងត្រូវបានជំនួសដោយឧបសម្ព័ន្ធទី១ថ្មី ដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The Schedule 1 of the license documents Nº 055 LD shall be replaced by new Schedule1 attached here with. |
| **ប្រការ ៣**<br>សេចក្តីសម្រេច និងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៥៥ ឯអ។ | **Article 3**<br>This decision and the attached revised Schedule shall be considered as a part of the license documents Nº 055 LD. |
| **ប្រការ ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃនៃឯកសារអាជ្ញាប័ណ្ណលេខ ០៥៥ ឯអ និងខ្លឹមសារ ដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល។ | **Article 4**<br>The other contents and conditions of the license document N° 055 LD with its revisions shall remain in force. |
| **ប្រការ ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៥៥ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០៥៥ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document Nº 055 LD has been deposited in order that the deposited license document Nº 055 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី… ខែ… ឆ្នាំ២០០៩

Phnom Penh, ..., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី១
# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី... នាថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC Nº ... DATED ...., 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យលោក ម៉ាក់ ខុម ធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺនៅទីប្រជុំជនផ្សារព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង និងសង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ។ | 1. The authorized distribution Areas, where Mr. Mak Khom has the right to provide the electricity distribution and supply services at Phsar Prey Sandek Town, Khum Prey Sluek, Trang Dicsrict and Sangkat Rokarkrav, Dounkeo Town, Takeo Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី កំណត់ដោយផែនទីកំណត់ព្រំប្រទល់ 055LD-map-Mak Khom-Revision 5-2009 ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution Areas is determined by the boundary map 055LD-map-Mak Khom-Revision 5-2009 attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក ម៉ាក់ ខុម មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះលោក ម៉ាក់ ខុម ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if Mr. Mak Khom intends to request the extension or the additional distribution areas then Mr. Mak Khom shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |